# រាជបណ្ឌិត្យសភាកម្ពុជា

## មជ្ឈមណ្ឌលសិក្សាចិន

*អត្ថបទស្រាវជ្រាវ៖*

# «យុទ្ធសាស្ត្រនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងវិថី»




*ដោយ៖ បណ្ឌិត* **ចាន់ ប៊ុន្នី**

*ខែមករា ឆ្នាំ២០១៩*

# «យុទ្ធសាស្ត្រនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងវិថី»

*ដោយៈ បណ្ឌិត* **ចាន់ ម៉ុន្នី**



អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសិក្សាចិន

## I. សេចក្តីផ្តើម

នៅក្នុងរបត់នៃសកលភាវូបនីយកម្មសេដ្ឋកិច្ច គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថីជាយុទ្ធសាស្ត្រសំខាន់ដែលដាក់ចេញថាជាការបើកចំហជុំទី២របស់ចិន (China's second round of opening-up) ហើយគេសង្ឃឹមថានឹងដើរតួនាទីយ៉ាងសំខាន់ឈានមុខក្នុងការប្រឈមជាមួយនឹងលទ្ធិគាំពារនិយមពាណិជ្ជកម្មដោយបង្កើតឱ្យមានការបើកចំហ ការរាប់បញ្ចូលគ្នា និងចែករំលែកនៃសកលភាវូបនីយកម្មសេដ្ឋកិច្ច។ វាទទួលភារកិច្ចជាប្រវត្តិសាស្ត្របី៖ ទី១. ជំរុញតំណភ្ជាប់ទៅវិញទៅមកខាងហេដ្ឋារចនាសម្ព័ន្ធ ទី២. ផ្តោតទៅលើទំហំសហប្រតិបត្តិការ និងសេវាពាណិជ្ជកម្ម និងទី៣. បង្កើតបណ្តាញតំបន់ពាណិជ្ជកម្មសេរីគ្រប់កម្រិត និងខុសៗគ្នា។

ស្នាដៃនេះ យើងនឹងពិនិត្យមើលអំពីគម្រោង និងការអនុវត្តគំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថីដែលជាមធ្យោបាយមួយដើម្បីកែលម្អទំនាក់ទំនងទ្វេភាគីជាមួយប្រទេសជិតខាងនិងមហាអំណាចនានា ដើម្បីប្រែក្លាយទៅជាមហាអំណាចធំមួយលើឆាកអន្តរជាតិ។ ក្នុងនេះដែរ យើងក៏នឹងលើកយកទំនាក់ទំនងរវាងប្រទេសកម្ពុជានិងគំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថីនេះ មករៀបរាប់ដោយសង្ខេបផងដែរ។

## II. គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថី

គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថី (BRI) នៃប្រទេសចិនបានបង្ហាញជាផ្លូវការនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៥ មិនមែនជាគម្រោងវិថីសូត្រថ្មីមួយនោះទេ។ ផ្ទុយទៅវិញ វាជាយុទ្ធសាស្ត្រអឺរ៉ាស៊ីប្រកបដោយមហិច្ឆតានិងរឹងមាំរបស់មហាអំណាចអភិវឌ្ឍថ្មី។ គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថីផ្អែកលើតំណភ្ជាប់ដែលមានស្រាប់និងបានគ្រោងទុកមកហើយ ចាប់ផ្តើមពីតំបន់ផ្សេងៗនៃប្រទេសចិន ឆ្ពោះទៅកាន់ពិភពលោកខាងក្រៅ។ វាត្រូវបានគាំទ្រដោយវិភាគទាន

ហិរញ្ញវត្ថុយ៉ាងសម្បើម ហើយវាហាក់ដូចជាបានបញ្ជាក់យ៉ាងច្បាស់លាស់ល្អជាងគម្រោងដូចៗគ្នាដទៃទៀត។

ប្រទេសចិនបានត្រួតត្រាផ្នែកសេដ្ឋកិច្ចអស់រយៈពេល១៨សតវត្សរ៍ក្នុងចំណោម២០សតវត្សរ៍ចុងក្រោយនេះ។ លោក ហ្សេម ហ្វែរហ្គ្រីវ(James Fairgrieve) ហូមេ លី(Homer Lea) ហ្ស៊ក បែរណាដ គ្រីស្សេ (George Bernard Cressey) និងអ្នកដទៃទៀតបានបញ្ជាក់អំពីសក្តានុពលរបស់ចិនជាមហាអំណាចធំមួយ។ បច្ចុប្បន្ននេះ ប្រទេសចិនហាក់បានប្រែក្លាយពីការប្រើកម្លាំងសេដ្ឋកិច្ចទៅជាអានុភាពនយោបាយ។

អ្នកវិភាគបរទេសភាគច្រើនបានសាទរចំពោះ BRI ថាជា«យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ» ឬជាការវាយលុកខាងភូមិសាស្ត្រនយោបាយនិងការទូត។ នៅគ្រាដែលមន្ត្រីចិនបានចាត់ទុកយុទ្ធសាស្ត្រនេះជា «ទស្សនវិស័យសេដ្ឋកិច្ចប្រកបដោយមហិច្ឆតាមួយនៃនយោបាយបើកចំហ និងសហប្រតិបត្តិការ» ជាគម្រោងដែលមានលក្ខណៈជាប្រព័ន្ធ គ្រប់គ្រងដោយ «ស្មារតីវិថីសូត្រ» ដែលស្វែងរកការបង្កើត«សហគមន៍មួយនៃការចែករំលែកផលប្រយោជន៍ វាសនា និងការទទួលខុសត្រូវ»(National Development and Reform Commission, NDRC)។ យ៉ាងណាក៏ដោយ BRI ជាការប្រឹងប្រែងប្រកបដោយមហិច្ឆតាបំផុតរបស់ចិនចាប់ពីពេលមានមេដឹកនាំថ្មី ជ្រើសរើសដោយសន្និបាតបក្សកុម្មុយនីស្តចិនលើកទី១៨ នៅខែវិច្ឆិកា ឆ្នាំ២០១២ មក។

វិថីសូត្របុរាណ ជាមធ្យោបាយសន្តិវិធីមួយសម្រាប់អនុវត្តសកម្មភាពពាណិជ្ជកម្មរវាងប្រទេសនិងប្រទេសនិងការផ្លាស់ប្តូរវប្បធម៌។ វិថីសូត្រដីគោកមានចម្ងាយជាង១០ ០០០ គីឡូម៉ែត្រពីប្រទេសចិនទៅក្រុងរ៉ូម អាចរំលឹកទៅដល់សម័យសន្តតិវង្សហាន (Han Dynasty, 206 BC - 220 AD) នៅពេលដែលរាជទូត Zhang Qian ត្រូវបានបញ្ជូនទៅភាគខាងលិចប្រទេសចិន ដើម្បីអភិវឌ្ឍទំនាក់ទំនងមិត្តភាព។ វិថីសូត្រសមុទ្របានចាប់ផ្តើមពីពេលដែលចិនចេញដំណើរទៅអាស៊ីអាគ្នេយ៍ ដែលគេហៅថា ណានយ៉ាង(Nanyang)។ ក្នុងសម័យសន្តតិវង្សសុង (Song Dynasty, 960 - 1279) អធិរាជចិនបានបង្កើតទំនាក់ទំនងជារដ្ឋចំណុះជាមួយរដ្ឋនៅណានយ៉ាង។

នៅខែតុលា ឆ្នាំ២០១២ សាស្ត្រាចារ្យ វ៉ាង ជីស៊ី(Wang Jisi) ជាអ្នកប្រាជ្ញចិនដំបូងបានលើកឡើងអំពីតម្រូវការរបស់ចិនដើម្បីធ្វើឱ្យរស់ឡើងវិញនូវវិថីសូត្របុរាណទាំងបីឆ្ពោះទៅអាស៊ីអាគ្នេយ៍ ទៅអាស៊ីខាងត្បូង និងអាស៊ីកណ្តាល។ មួយឆ្នាំក្រោយមក គំនិតផ្តួចផ្តើមរបស់ចិនបានចាប់កំណើតឡើង។ ប្រធានាធិបតី ស៊ី ជីនពីង នៅខែកញ្ញា ឆ្នាំ២០១៣ បានថ្លែងនៅសាកលវិទ្យាល័យណាហ្សារបៃយេវ នៃប្រទេសកាហ្សាក់ស្ថាន អំពាវនាវឱ្យស្តារឡើងវិញនូវវិថីសូត្របុរាណ ដោយបង្កើត«ខ្សែក្រវាត់សេដ្ឋកិច្ចវិថីសូត្រ»។ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ នាយករដ្ឋមន្ត្រី លី ខឺឈាង បាននិយាយអំពី«វិថីសូត្រសមុទ្រថ្មី» នាឱកាសកិច្ចប្រជុំអាស៊ាន

ចិនលើកទី១៦ នៅប្រទេសព្រុយណេ។ ចុងក្រោយនេះ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៥ គណៈកម្មការកំណែទម្រង់និងអភិវឌ្ឍជាតិចិន (NDRC) ក្រសួងការបរទេស និងក្រសួងពាណិជ្ជកម្ម បានបោះពុម្ពឯកសារដំបូង ក្រោមឈ្មោះថា«ទស្សនវិស័យនិងសកម្មភាពស្តីពីការរួមគ្នាកសាងខ្សែក្រវាត់សេដ្ឋកិច្ចវិថីសូត្រនិងវិថីសូត្រសមុទ្រសតវត្សរ៍ទី២១»[1]។

គំនិតផ្តួចផ្តើមផ្តើមខ្សែក្រវាត់និងវិថី ឆ្លងកាត់ទ្វីបអាស៊ី អឺរ៉ុប និងអាហ្វ្រិក ដែលតភ្ជាប់សេដ្ឋកិច្ចអាស៊ីបូព៌ាទៅកាន់សេដ្ឋកិច្ចអឺរ៉ុប និងព័ទ្ធជុំវិញបណ្តាប្រទេសដែលកំពុងមានកំណើនផលិតផលក្នុងស្រុក(GDP) ក្នុង១៥ឆ្នាំខាងមុខនេះ។

ខ្សែក្រវាត់សេដ្ឋកិច្ចវិថីសូត្រ នឹងតភ្ជាប់ប្រទេសចិនទៅនឹងបណ្តាប្រទេសនៅអាស៊ីកណ្តាល រុស្ស៊ី និងរដ្ឋបាល់ទិក តភ្ជាប់ប្រទេសចិនទៅនឹងឈូងសមុទ្រពែក្ស និងសមុទ្រម៉េឌីទែរ៉ាណេ តាមរយៈអាស៊ីកណ្តាល និងអាស៊ីខាងលិច និងតភ្ជាប់ប្រទេសចិនជាមួយអាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង និងមហាសមុទ្រឥណ្ឌា។ វិថីសូត្រសមុទ្រសតវត្សរ៍ទី២១ នឹងភ្ជាប់ឆ្នេរសមុទ្រចិនទៅទ្វីបអឺរ៉ុប កាត់តាមសមុទ្រចិនខាងត្បូង និងមហាសមុទ្រឥណ្ឌា និងឆ្នេរសមុទ្រចិនកាត់តាមសមុទ្រចិនខាងត្បូងទៅកាន់ប៉ាស៊ីហ្វិកខាងត្បូង។

គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថី មិនមែនជាផ្លូវតែមួយនោះទេ។ យោងតាមអត្ថបទរបស់ NDRC រួមមាន៖ ផ្លូវដីអឺរ៉ាស៊ីថ្មី ច្រករបៀងសេដ្ឋកិច្ចចិន-ម៉ុងហ្គោលី-រុស្ស៊ី ច្រករបៀងសេដ្ឋកិច្ចចិន-អាស៊ីកណ្តាល-អាស៊ីខាងលិច និងច្រករបៀងសេដ្ឋកិច្ចចិន-ឧបទ្វីបឥណ្ឌូចិន ក៏ដូចជាច្រករបៀងសេដ្ឋកិច្ចចិន-ប៉ាគីស្ថាន និងច្រករបៀងសេដ្ឋកិច្ចបង់ក្លាដែស-ចិន-ឥណ្ឌា-ភូមា ជាដើម។

គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថី បានបញ្ជាក់ថាមានវិស័យសំខាន់ៗ៥៖ ការសម្របសម្រួលនយោបាយ តំណភ្ជាប់សមត្ថភាព គ្មានរបាំងពាណិជ្ជកម្ម សមាហរណកម្មហិរញ្ញវត្ថុ និងចំណងប្រជាជននិងប្រជាជន។ ការសម្របសម្រួលនយោបាយ មានន័យថាបណ្តាប្រទេសពាក់ព័ន្ធនឹងចូលរួមរៀបចំ«យុទ្ធសាស្ត្រអភិវឌ្ឍនិងនយោបាយ រកមធ្យោបាយដោះស្រាយនូវផែនការនិងវិធានការសម្រាប់សហប្រតិបត្តិការតំបន់» នឹងដោះស្រាយបញ្ហាដែលកើតឡើងនានាតាមរយៈកិច្ចពិភាក្សា ហើយនិងរួមគ្នាផ្តល់គោលនយោបាយគាំទ្រការអនុវត្តសហប្រតិបត្តិការនិងការអនុវត្តគម្រោងធំៗ។ តំណភ្ជាប់ខាងកស្តុភាររួមមាន៖ គម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក មហាវិថី ផ្លូវអាកាស ទូរគមនាគមន៍ បំពង់បង្ហូរនិងឧស្ម័នធម្មជាតិ និងកំពង់ផែ ប្រព័ន្ធស្តង់ដាបច្ចេកទេស ច្រករបៀងអន្តរជាតិ ដើម្បីបង្កើតបណ្តាញហេដ្ឋារចនាសម្ព័ន្ធមួយតភ្ជាប់អនុតំបន់ទាំងអស់នៅអាស៊ី និងរវាងអាស៊ី អឺរ៉ុប និងអាហ្វ្រិក។

មូលនិធិវិថីសូត្រ (the Silk Road Fund) ត្រូវបានប្រកាសដោយប្រធានាធិបតី ស៊ី ជីនពីង នៅខែវិច្ឆិកា ឆ្នាំ២០១៤ ត្រូវបានចាប់ដំណើរការនៅខែកុម្ភៈ ឆ្នាំ២០១៥ ជាមួយទឹក

[1] Irina Ionela Pop, *Strengths and Challenges of China's "One belt, One road" Initiative*. 2016.

ប្រាក់៤០ប៊ីលានដុល្លារ។ វាបង្កើតឡើងដោយមានអ្នកម្ចាស់ហ៊ុនដូចជា China's State Administration of Foreign Exchange, the China Investment Corp, the Export-Import Bank of China, and the China Development Bank។ វាផ្តល់ហិរញ្ញវត្ថុវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ ធនធាននិងឧស្សាហកម្ម និងសហប្រតិបត្តិការ ហិរញ្ញវត្ថុឆ្លងកាត់អាស៊ី។

ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី(Asian Infrastructure Investment Bank, AIIB) ក៏បានបង្កើតឡើងសម្រាប់ការផ្តល់ទស្សនវិស័យនៃអភិបាលកិច្ចនិងការអភិវឌ្ឍ។ វាផ្តោតសំខាន់ទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងវិស័យផលិតកម្មដទៃទៀតនៅអាស៊ីរួមមាន៖ ថាមពលនិងអគ្គិសនី ការដឹកជញ្ជូន ទូរគមនាគមន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទនិងកសិកម្ម ការផ្គត់ផ្គង់ទឹកនិងអនាម័យការពារបរិស្ថាន ការអភិវឌ្ឍទីក្រុង និងការដឹកជញ្ជូនទំនិញ(Logistics)។

ប្រទេសចិនបានកំណត់វេទិកាអន្តរជាតិនិងតំបន់មួយចំនួន ដើម្បីគាំទ្រឬអនុវត្តគម្រោង BRI។ នេះបើយោងតាមសេចក្តីថ្លែងការណ៍ចក្ខុវិស័យ ប្រទេសចិនបានកំណត់វេទិកាថ្នាក់តំបន់និងអន្តរជាតិ សម្រាប់ការអនុវត្ត BRI រួមមាន៖

- អង្គការកិច្ចសហប្រតិបត្តិការសៀងហៃ (SCO)
- អាស៊ានបូកចិន (10+1)
- កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក (APEC)
- កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM)
- កិច្ចសន្ទនាអំពីកិច្ចសហប្រតិបត្តិការអាស៊ី (ACD)
- សន្និសីទស្តីអំពីអន្តរកម្មនិងវិធានការកសាងទំនុកចិត្តក្នុងអាស៊ី (CICA)
- វេទិកាកិច្ចសហប្រតិបត្តិការចិន-អារ៉ាប់ (CASCF)
- ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រចិន កិច្ចសន្ទនាយុទ្ធសាស្ត្រនៅមហាអនុតំបន់ទន្លេមេគង្គ អនុតំបន់ (GMS)
- កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងមជ្ឈមកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់អាស៊ី (CAREC)។

មកដល់ពេលនេះ គម្រោង«ខ្សែក្រវ៉ាត់និងវិថី» របស់មហាយក្សចិននេះ ទទួលបានការចូលរួមនិងគាំទ្រពីស្ថាប័នអន្តរជាតិនិងប្រទេសចំនួនជាង១០០ នៅក្នុងពិភពលោក[2]។

[2] https://khmer.voanews.com/a/analysts-see-benefits-for-cambodia-from-china-s-one-belt-initiative/3853546.html




## III. គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថីនិងប្រទេសកម្ពុជា

ប្រទេសកម្ពុជាបានប្រកាសគាំទ្រគំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថីរបស់ចិន ដែលបានប្រកាសឡើងដោយប្រធានាធិបតីចិន កាលពីខែកញ្ញា ឆ្នាំ២០១៣។ តាមរយៈគំនិតផ្តួចផ្តើមនេះ ប្រទេសកម្ពុជាបានទទួលជំនួយ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងវិស័យផ្សេងៗទៀតជាច្រើន។




«ខ្សែក្រវាត់និងវិថី» (One Belt One Road) គឺជាគំនិតផ្តួចផ្តើមយ៉ាងធំទូលំទូលាយរបស់ចិនដើម្បីលើកកម្ពស់ការតភ្ជាប់សេដ្ឋកិច្ច និងការដោះដូរពាណិជ្ជកម្ម ជាពិសេសរវាង

បណ្ដាប្រទេសនៅអាស៊ី អឺរ៉ុប និងអាហ្វ្រិក។ «ខ្សែក្រវាត់និងវិថី» ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៣។ គិតត្រឹមឆ្នាំ២០១៦ ទំហំទឹកប្រាក់វិនិយោគក្នុងគម្រោងរបស់ប្រទេសកុម្មុយនីស្ត ចិន មានចំនួនប្រមាណ៩០០ប៊ីលានដុល្លារអាម៉េរិក។ កម្ពុជាបានចូលរួមក្នុងគម្រោងនេះកាល ពីចុងឆ្នាំ២០១៦ ជាពេលដែលលោក ស៊ី ជីនពីង បានធ្វើដំណើរទស្សនកិច្ចមកកម្ពុជា។

ក្រសួងពាណិជ្ជកម្មកម្ពុជាកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ បានចុះហត្ថលេខា លើអនុស្សរណៈយោគយល់គ្នាជាមួយប្រទេសចិន ចំនួន១២ ដែលមានតម្លៃសរុបជាង៨០ លានដុល្លារអាម៉េរិកក្នុងវេទិកាវិនិយោគធុរកិច្ច និងទេសចរណ៍នៃពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ានលើកទី១៥។ អនុស្សរណៈយោគយល់ចំនួន១២ខាងលើ គឺនឹងគ្របដណ្ដប់លើកិច្ច សហប្រតិបត្តិការលើវិស័យសំខាន់ៗរួមមាន៖ ១) ការធ្វើធុរកិច្ច-ពាណិជ្ជកម្ម ២) ការបណ្ដុះ បណ្ដាលធនធានមនុស្សផ្នែកមគ្គុទេសក៍ទេសចរណ៍ និងផ្នែកវិស្វកម្ម (ផ្លូវដែកល្បឿនលឿន ទំនប់វារីអគ្គិសនី និងប្រព័ន្ធធារាសាស្ត្រ) ៣) ការស្ថាបនាផ្លូវយន្តហោះ ៤) ការបង្កើតមហា វិទ្យាល័យស្រាវជ្រាវឧស្សាហកម្ម និង ៥) ការកសាងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលទេសចរណ៍ ចិន-អាស៊ាន(Sino-ASEAN)។

ប្រទេសចិនបានវិនិយោគលើគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាច្រើននៅកម្ពុជា រួមមាន៖ គម្រោងសាងសង់ស្ពានឆ្លងទន្លេមេគង្គ គម្រោងសាងសង់តំបន់សេដ្ឋកិច្ចពិសេសក្រុង ព្រះសីហនុ ក្រុងបាវិត ក្រុងប៉ោយប៉ែត គម្រោងសាងសង់ផ្លូវល្បឿនលឿន គម្រោងសាង សង់ទំនប់វារីអគ្គិសនី។ល។

រដ្ឋាភិបាលកម្ពុជានិងចិន បានខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីដល់ កម្រិតកំពូលមួយ គឺជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយចាប់ពីឆ្នាំ២០១០មក។ «គំនិតផ្ដួច ផ្ដើមខ្សែក្រវាត់និងវិថី» សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ កំពុងសហប្របត្តិការរវាង ប្រទេសទាំងពីរ កំពុងត្រូវបានពង្រឹងថែមទៀតលើវិស័យសំខាន់ៗមួយចំនួនជាប្រយោជន៍ដល់ ការកែលម្អការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសទាំងពីរ រួមមានការពង្រឹងផលិតភាពសេដ្ឋកិច្ច ការបង្កើនពាណិជ្ជកម្ម ព្រមទាំងការលើកស្ទួយឧស្សាហកម្ម ទេសចរណ៍ ការវិនិយោគ និងកសិកម្ម។ ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលកម្ពុជាបានត្រៀមខ្លួនរួចជាស្រេច ដើម្បី ចូលរួមយ៉ាងសកម្មក្នុងយន្តការសហប្រតិបត្តិការទាំងឡាយនៃគំនិតផ្ដួចផ្ដើមខ្សែក្រវាត់និងវិថី ដើម្បីវឌ្ឍនភាព និងការរីកចម្រើនរួមនៃតំបន់ និងសកលលោក[3]។

## IV. **សេចក្ដីសន្និដ្ឋាន**

យោងតាមអ្នកកាន់លទ្ធិខុងជឺនិយមបានរៀបរាប់ថា ចិនជាប្រទេសសន្តិភាពប្លែក ជា ប្រទេសដែលការពារនិងមិនឈ្លានពានគេឯង។ ម្យ៉ាងទៀត ប្រទេសចិនបានបង្ហាញខ្លួនថាជា

[3] http://www.samdechhunsen.gov.kh/index.php/1561-2017-05-15-10-46-30

ប្រទេសមហាអំណាចធំមួយដែលមានតួនាទីជាប្រវត្តិសាស្ត្រក្នុងឆាកអន្តរជាតិ ដោយសារតែទំហំរបស់ខ្លួន វប្បធម៌ និងសេដ្ឋកិច្ច។ នយោបាយការបរទេសចិន គេអាចសង្ខេបខ្លីរវាង«*ការទូតជាមួយប្រទេសជិតខាង*» និង«*ការទូតជាមួយមហាអំណាចធំៗ*»។

នៅក្នុងបរិបទនេះ គោលដៅរបស់ចិនទាំងក្នុងរយៈពេលវែងនិងរយៈពេលខ្លីរួមមាន៖ ស្ថិរភាពផ្ទៃក្នុង រក្សាកំណើនសេដ្ឋកិច្ច កំណែទម្រង់ស៊ីជម្រៅ និងបើកចំហទៅពិភពលោកខាងក្រៅ បង្កើនអំណាចស្រទន់របស់ខ្លួន កែលម្អទំនាក់ទំនងជាមួយប្រទេសជិតខាង សន្តិសុខថាមពល និងរក្សាតុល្យភាពទំនាក់ទំនងជាមួយមហាអំណាចធំៗ អ្នកបង្កើតច្បាប់ក្នុងស្ថាប័នអភិបាលកិច្ចសកល និងរួមវិភាគទានក្នុងសេដ្ឋកិច្ចសកល។

គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថី ហាក់ដូចជាសមស្របទៅនឹងការវិវឌ្ឍនយោបាយ និងសេដ្ឋកិច្ចបច្ចុប្បន្ននៃប្រទេសចិន ទៅតាមលំនាំនៃទំនាក់ទំនងអន្តរជាតិ។ ប៉ុន្តែយុទ្ធសាស្ត្រនេះនឹងនាំឱ្យមានបញ្ហាប្រឈមមួយចំនួននៅក្នុងប្រទេសដៃគូដូចជា ទីតាំងមិនល្អ ឆ្ងាយពីទីផ្សារតម្លៃខ្ពស់ ពន្ធគយ ពុករលួយ អស្ថិរភាពនយោបាយនិងភេរវកម្ម និងបញ្ហាប្រឈមក្នុងបញ្ហាផ្ទៃក្នុងរបស់ខ្លួន ភាពតានតឹងជាមួយប្រទេសជិតខាង និងការប្រជែងជាមួយមហាអំណាចដទៃទៀត។

យ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថីហាក់ដូចជាបានបញ្ចេញឱ្យឃើញច្បាស់ជាងគម្រោងដូចគ្នាដទៃទៀត ប្រសិនបើយើងពិចារណាទៅលើអំណាចស្រទន់របស់គេ និងសកម្មភាពការទូតដទៃទៀត គម្រោងជាយុទ្ធសាស្ត្រនិងការគ្រប់គ្រង ប្រកពហិរញ្ញវត្ថុ និងអំណាចឆន្ទៈនៃវជនរបស់គេផងដែរ។

ចុងក្រោយនេះ យើងនឹងផ្តល់ជូនជាអនុសាសន៍មួយចំនួនទាក់ទងនឹងគំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថីរបស់ចិន៖

១. អ្នករៀបចំផែនការចិន គួរតែកំណត់ឱ្យបានច្បាស់ពីគោលបំណងម្ចាស់ភាគហ៊ុន និងគម្រោងនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថី។
២. ប្រទេសចិនពុំបានធានាថា កំណើនសេដ្ឋកិច្ចនឹងមាននិរន្តរភាព។ ដូច្នេះ ចិនត្រូវតែចែករំលែកពីហានិភ័យនៃការវិនិយោគជាមួយប្រទេសដៃគូ។
៣. ប្រទេសចិននឹងត្រូវកែលម្អតួនាទីរបស់ខ្លួនក្នុងប្រទេសជិតខាងដោយបង្ហាញពីឆន្ទៈដោះស្រាយជម្លោះដោយសន្តិវិធីនិងគតិយុត្ត និងជំរុញការអភិវឌ្ឍរួម។
៤. ប្រទេសចិនត្រូវតែកែលម្អទំនាក់ទំនងរបស់ខ្លួនជាមួយនឹងមហាអំណាចនានាលើកតម្កើងផលប្រយោជន៍ជាតិខ្លួន ដោយសម្របតាមរបៀបអន្តរជាតិ និងយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការ៕

# ឯកសារយោងនិទ្ទេស

ស៊ី ជីនពីង : *អភិបាលកិច្ចប្រទេសចិន* ២០១៧

Chi Fulin, Zhu Jianting, *The Second Round of Opening-Up - China's Choice at The Crossroads of Globalization*, 2017.

Friends of the Earth United States, *China's Belt and Road Initiative*. An Introduction. December 2016.

Irina Ionela Pop, *Strengths and Challenges of China's One belt, One road Initiative*. February 2016.

Wang Jiapei, *The Belt and Road Initiative and Its Impact on Asia-Europe Connectivity*. July 2016.